ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សុន្ទរកថា

## សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី
## នៃរាជរដ្ឋាភិបាលកម្ពុជា

ថ្លែងក្នុងពិធីបើក «ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» លើកទី១៦ ឆ្នាំ២០២២

- សូមក្រាបថ្វាយបង្គំ **សម្តេច ព្រះមហាសង្ឃរាជាទាំងពីរគណៈ** សម្តេចព្រះមហាសុមេធាធិបតី ព្រះរាជាគណៈសង្ឃ និងព្រះថេរានុត្ថេរៈ ជាបព្វជិត ក្នុងព្រះពុទ្ធសាសនា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់
- សូមក្រាបថ្វាយបង្គំ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះករុណាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈ
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល លោកឧកញ៉ា អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បញ្ញវន្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងស្ថានបេសកកម្មនានាប្រចាំនៅកម្ពុជា

- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន ឬតំណាងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- តំណាងគ្រប់និកាយសាសនា សិស្ស និស្សិត បងប្អូន កូន ក្មួយ និងជនរួមជាតិទាំងអស់ ជាទីស្រឡាញ់រាប់អាន !

ថ្ងៃនេះ ខ្ញុំ និងភរិយាខ្ញុំ មានក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដោយបានមកចូលរួមជាថ្មីក្នុងកម្មវិធី **ទិវាជាតិប្រឆាំងការជួញដូរមនុស្ស** បន្ទាប់ពីបានផ្អាកការជួបជុំទ្រង់ទ្រាយធំ អស់រយៈពេលពីរឆ្នាំក្នុងអំឡុងពេល នៃការរាតត្បាតដោយជំងឺកូវីដ-១៩ ។ ឆ្នាំ២០២២នេះ យើងមានឱកាសជាថ្មី ក្នុងការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ « **រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព**!» ដែលស្របទៅទស្សនវិស័យ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរក្សានូវសន្តិសុខ សុវត្ថិភាពសង្គម ដើម្បីជាមូលដ្ឋានបង្អែក នៃការអភិវឌ្ឍន៍ជាតិគ្រប់វិស័យក្នុងរយៈពេលវែង ។ ខ្ញុំសូមស្វាគមន៍ និងសូមថ្លែងអំណរព្រះគុណ និងអំណរគុណ ចំពោះព្រះវត្តមាន និងវត្តមានយ៉ាងកុះកររបស់ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ភ្ញៀវជាតិ និងអន្តរជាតិពីគ្រប់មជ្ឈដ្ឋាន នៅក្នុងកម្មវិធីដ៏មានសារសំខាន់នេះ ដែលជាការបង្ហាញនូវស្មារតីសាមគ្គីភាព និងការយកចិត្តទុកដាក់ចំពោះការងារប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប និងការការពារសិទ្ធិមនុស្សនៅកម្ពុជា ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែងបានប្រារព្ធរៀបចំកម្មវិធីទិវាជាតិនេះ ជារៀងរាល់ឆ្នាំ យ៉ាងអធិកអធមទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងតាមបណ្តាសាលារៀនគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ដែលមានអ្នកចូលរួម រហូតដល់រាប់សែននាក់ ។ នេះជាយុទ្ធនាការ

អប់រំផ្សព្វផ្សាយដ៏ធំមួយរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីបំផុសការយល់ដឹងយ៉ាងទូលំទូលាយអំពីព្រឹត្តិការណ៍ ស្ថានភាព និងនិន្នាការនៃអំពើជួញដូរមនុស្ស ដែលបង្កគ្រោះមហន្តរាយដល់មនុស្ស ក្មេង ចាស់ ប្រុស ស្រី និងដល់សង្គមជាតិឥតឈប់ឈរ ទាំងក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងនៅតាមបណ្តាប្រទេសក្នុងតំបន់ និងក្នុងពិភពលោក ហើយក៏ដូចជាការដាស់តឿនក្រើនរំលឹកដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់ភេទ គ្រប់វ័យ គ្រប់ស្ថានភាព គ្រប់មជ្ឈដ្ឋាន ឲ្យប្រុងប្រយ័ត្នចំពោះល្បិចកលថ្មីៗរបស់ ជនល្មើសជួញដូរមនុស្ស ។ ទន្ទឹមនឹងនោះ កម្មវិធីនេះ ក៏ជាការផ្សព្វផ្សាយ អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា ក្នុងការប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីការពារសុវត្ថិភាព និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជនកម្ពុជា និងមនុស្សជាតិទូទៅ ។

ក្រៅពីឧបទ្ទវហេតុដ៏អាក្រក់ជាច្រើនដែលកើតមាន រួមទាំងគ្រោះធម្មជាតិមានខ្យល់ព្យុះ ខ្យល់កន្ត្រាក់ គ្រោះទឹកជំនន់ បំណាក់ដី រលកកំដៅ ភ្លើងឆេះព្រៃ គ្រោះរាំងស្ងួត ព្រមជាមួយនឹងវិបត្តិជម្លោះប្រដាប់អាវុធ ការទន្ទ្រានឈ្លានពានដោយអំណាច ដើម្បីមហិច្ឆិតាក្នុងការដណ្តើមអំណាចត្រួតត្រា ការបង្កើតអាវុធមហាប្រល័យ ដើម្បីបង្ហាញឧត្តមភាព គម្រាមពិភពលោក ជាដើម បានបំផ្លាញពិភពលោកដ៏ស្រស់ស្អាតឲ្យវិនាសអន្តរាយ ធ្វើឲ្យមនុស្សក្មេង ចាស់ ប្រុសស្រីរាប់លាននាក់ បាននិងកំពុងតែរស់ក្នុងសភាពភ័យខ្លាច និងរងនូវគ្រោះ យ៉ាងលំបាកវេទនាជារៀងរាល់ថ្ងៃ ។

ទន្ទឹមនឹងនោះ ការរាតត្បាតនៃជំងឺឆ្លងដ៏កាចសាហាវ ជាពិសេសជំងឺកូវីដ-១៩ ក៏នៅអូសបន្លាយ មិនទាន់ផុតរលត់នៅឡើយ ហើយក៏កំពុងតែបំប្លែងទៅជាមេរោគថ្មីៗ

កាន់តែគ្រោះថ្នាក់ដល់ជីវិតមនុស្ស និងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព ជីវភាពរស់នៅរបស់ប្រជាជន និងសេដ្ឋកិច្ចនៅទូទាំងពិភពលោក ។ ប្រទេសខ្លះឈានដល់ខ្វះស្បៀង ទ្រព្យ អត់ ឃ្លាន ខ្វះថ្នាំសង្កូវ ខ្វះទាំងវ៉ាក់សាំងការពារ និងថ្នាំព្យាបាល កូវីដ-១៩ ហើយបាន និងកំពុងបន្តឆ្លងយ៉ាងឆាប់រហ័ស ពីម្នាក់ ទៅម្នាក់ ។ តាមទិន្នន័យក្នុងឆ្នាំ ២០២១ នៅបណ្តាប្រទេសក្នុងពិភពលោក មានអ្នកឆ្លងជាង **២៥០លាននាក់** និងមានមនុស្សស្លាប់ដោយកូវីដ-១៩ ជាងប្រាំមួយលាននាក់រួចហើយ ក្នុងនោះក្នុងទ្វីបអាស៊ី ក៏មានអ្នកឆ្លងសរុប ប្រមាណ **៦៥លាននាក់** និងមានអ្នកស្លាប់ប្រមាណ **០១លាននាក់** ផងដែរ ហើយក៏នៅតែបន្តឆ្លងឥតឈប់ឈររៀងរាល់ថ្ងៃ រហូតដល់បច្ចុប្បន្ន ។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាយើង ក៏បានទទួលរងឥទ្ធិពលធ្ងន់ធ្ងរពីកូវីដ-១៩ មិនខុសពីប្រទេសដទៃដែរ ដោយបានធ្វើឲ្យមានអ្នកឆ្លងសរុប ប្រមាណ **១៣៨.១៥៧ នាក់** និងបានស្លាប់ **៣.០៥៦នាក់** (តួរលេខគិតត្រឹមថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២) ដែលអត្រា ឆ្លង និង អត្រានៃការស្លាប់នេះ កើនខ្ពស់ ក្នុងឆ្នាំ២០២១ ។ ទោះបីជាយ៉ាងនេះក្តី វិបត្តិកូវីដ-១៩ នេះ ត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស។ គិតមកដល់ ខែធ្នូ ឆ្នាំ២០២២ នេះ ករណីឆ្លងថ្មីប្រចាំថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺនៅក្រោម **១០នាក់** និងមិនទាន់មានអ្នកស្លាប់ថ្មី ដោយកូវីដ-១៩ នៅឡើយទេ ចាប់ពីខែសីហា ឆ្នាំ២០២២ មក។ ខ្ញុំសូមឆ្លៀតឱកាសនេះ ជំនួសមុខរាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មី ចំពោះបណ្តាប្រទេសជាមិត្តទាំងឡាយ ដែលតែងផ្តល់ការយកចិត្តទុកដាក់ កិច្ចសហការ និងការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកាលៈទេសៈលំបាកដោយបានផ្តល់នូវវ៉ាក់សាំងគ្រប់ប្រភេទ ចំពោះប្រជាជនកម្ពុជា គួបផ្សំ នឹងលទ្ធភាពនៃការបញ្ជាទិញរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើឲ្យយើងមានលទ្ធភាពអនុវត្តនយោបាយចាក់ស្រោចវ៉ាក់

សាំង ការពារជំងឺកូវីដ-១៩ បានទាន់ពេលវេលា ។ ខ្ញុំសូមថ្លែងអំណរគុណដល់ជនរួមជាតិទាំងអស់ ដែលតែងតែចូលរួមគាំទ្រ និងអនុវត្តនូវវិធានការទាំងឡាយ ដែលរាជរដ្ឋាភិបាលបានកំណត់ រហូតទទួលបានជោគជ័យតាមការគ្រោងទុក ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់ទីភ្នាក់ងារអង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា ជាពិសេស អង្គការ WHO, IOM, UNICEF, UNFPA, UNDP, UNODC និងទីភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀតក្នុងតំបន់ ក៏ដូចជា សហគមន៍អឺរ៉ុប អង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ ស្ថានតំណាងពីបណ្តាប្រទេសនានាក្នុងសាកលលោក ព្រមទាំងវិនិយោគិនបរទេស និងក្នុងស្រុក ដែលតែងតែនៅជាមួយយើងខ្ញុំ និងរួមដៃគ្នា រកគ្រប់មធ្យោបាយ ពុះពារឧបសគ្គ ដើម្បីដោះស្រាយបញ្ហាបានគ្រប់ស្ថានភាពជារៀងរហូតមក ។

នេះជាជោគជ័យ ដ៏ធំធេងថ្មីមួយទៀត សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលអាចទប់ស្កាត់ និងកាត់បន្ថយ ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ បានល្អប្រសើរ ក្រោមគោលនយោបាយ **«ចាក់ស្រោចវ៉ាក់សាំង»** ចាប់ពីកុមារអាយុបីឆ្នាំ ឡើងទៅ រួមទាំងជនបរទេស ដែលកំពុងរស់នៅលើទឹកដីកម្ពុជា **វិធានការ «បីកុំ បីការពារមួយចូលរួម»** និង**វិធានការ «កាត់ផ្តាច់ចរន្តនៃការឆ្លងទៅសហគមន៍»** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និង ដោយមានការចូលរួមយ៉ាងសកម្ម ពីមន្ត្រីរដ្ឋាភិបាលគ្រប់ថ្នាក់ គ្រប់វិស័យ ដៃគូជាតិ និងអន្តរជាតិ ជាពិសេស ក្រុមគ្រូពេទ្យស្ម័គ្រចិត្តយ៉ាងច្រើនកុះករ ដែលទទួលបានការប្រសិទ្ធនាមថា ជា **«កងទ័ពអាវស ក្នុងសមរភូមិ កូវីដ-១៩»** រហូតធ្វើឲ្យកម្ពុជាវិលមករកប្រក្រតីភាពតាមគន្លងថ្មីដូចសព្វថ្ងៃ ។

ទោះបីជាយ៉ាងនេះក្តី ចរន្តនៃការវិលត្រឡប់មកវិញដោយឥតគ្រោងទុករបស់ពលករកម្ពុជា ពីប្រទេសគោលដៅ ក្នុងអំឡុងកូវីដ-១៩ ជាពិសេស ក្នុងឆ្នាំ២០២០ និង២០២១ បានកើនរហូតដល់ជាង **៣០ម៉ឺននាក់** ។ គឺក្នុងដំណាក់កាលនេះហើយ ដែលការគ្រប់គ្រងព្រំដែន មានភាពប្រឈម ស្មុគស្មាញ ដោយចំនួននៃពលករវិលត្រឡប់ កើនឡើងយ៉ាងគំហុក ជារៀងរាល់ថ្ងៃ ។ ព្រះរាជាណាចក្រកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ជាចម្បង លើការការពារសុខភាព និងអាយុជីវិតប្រជាពលរដ្ឋជាធំ ជាជាងការផ្តោតលើការរឹតបន្តឹងលើភាពស្របច្បាប់ នៃលំហូរទេសន្តរប្រវេសន៍ ។ គឺក្នុងដំណាក់កាលនេះហើយ ដែលជនទេសន្តរប្រវេសន៍បរទេសខុសច្បាប់ជាច្រើន មានឱកាស បន្លំខ្លួន ចូលមកកម្ពុជា ដោយខុសច្បាប់ និងបានសម្ងំលាក់ខ្លួន ធ្វើការងារជាមួយនិយោជក ទុច្ចរិតមួយចំនួន ដែលបង្កើតបានជាបទល្មើសយ៉ាងអាណាធិបតេយ្យ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ស្ថិតក្នុងស្ថានភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជា មិនបានព្រងើយកន្តើយឡើយ បានដាក់ចេញនូវវិធានការប្រតិបត្តិការ ដើម្បីរុករក បង្ក្រាប និងបោសសម្អាតបទល្មើសជួញដូរមនុស្ស គ្រប់ទម្រង់ និងបទល្មើសពាក់ព័ន្ធដទៃទៀត យ៉ាងសកម្ម តាមវិធានការច្បាប់ រហូតធ្វើឲ្យកម្ពុជា វិលត្រឡប់មករកស្ថានភាពសុវត្ថិភាព និងសន្តិសុខជាប្រក្រតីឡើងវិញ នៅទូទាំងផ្ទៃប្រទេស ។

**សម្តេច ព្រះមហាសង្ឃរាជាទាំងពីរគណៈ ព្រះរាជាគណៈ និងព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈ**

**ព្រះករុណាព្រះមហាក្សត្រ និងព្រះមហាក្សត្រីយ៍ សម្តេចម៉ែជាទីគោរពសក្ការៈ**

**សម្តេច ឯកឧត្តម លោកជំទាវ និងបងប្អូនជនរួមជាតិ ជាទីស្រឡាញ់ រាប់អាន**

ព្រះរាជាណាចក្រកម្ពុជា បានបង្កើតស្នាដៃល្អៗជាច្រើន ស្ទើរគ្រប់វិស័យ សម្រាប់ប្រទេសជាតិផង និងការរួមចំណែកកសាងសន្តិសុខ សុវត្ថិភាព និងការរីកចម្រើន សម្រាប់តំបន់ និងអន្តរជាតិផង ។

ជោគជ័យនៃការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ ដែលកម្ពុជាធ្វើជា **«ម្ចាស់ផ្ទះប្តូរវេន»** ក្រោមប្រធានបទ **«អាស៊ាន រួមគ្នាធ្វើ៖ ដោះស្រាយភាពប្រឈមទាំងអស់គ្នា»** និងកិច្ចប្រជុំវិស័យពាក់ព័ន្ធជាច្រើនទៀត បានឆ្លុះបញ្ចាំងពីស្ថានភាពសុវត្ថិភាព និងសន្តិសុខយ៉ាងល្អប្រសើររបស់កម្ពុជា ដែលអាចផ្តល់នូវកិច្ចស្វាគមន៍ ថ្នាក់ដឹកនាំកំពូល និងគណៈប្រតិភូនៃបណ្តាប្រទេសក្នុងតំបន់និងលើពិភពលោក រួមទាំងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិរាប់ពាន់នាក់ ឲ្យមកស្នាក់នៅធ្វើទស្សនកិច្ចកំសាន្ត ចូលរួមកិច្ចប្រជុំ និងសម្រេចបានលទ្ធផលយ៉ាងធំធេង គួរជាទីមោទនៈ ប្រកបដោយសុវត្ថិភាព សប្បាយរីករាយ និងជោគជ័យ ហួសពីការរំពឹងទុក ។ នេះជាសក្ខីភាពជាក់ស្តែង ដែលបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងតែមានសុវត្ថិភាព សន្តិសុខ និងការគោរពសិទ្ធិមនុស្ស ក្រោមកិច្ចសហការផ្ទៃក្នុងជាតិ និងជាមួយអន្តរជាតិយ៉ាងពេញលេញ ។

ព្រះរាជាណាចក្រកម្ពុជា នៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេស អំពើជួញដូរមនុស្ស និងបន្តអនុវត្តរាល់បទដ្ឋានដែលជាប្រយោជន៍ដល់ការលើកកម្ពស់ការគោរពសិទ្ធិ និងកិច្ចការពារសុវត្ថិភាពមនុស្សជាតិ ។ កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការរៀបចំ អនុម័តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលហៅកាត់ថា GCM ហេតុត្រូវ បានការទទួលស្គាល់ពីអង្គការសហប្រជាជាតិផ្នែកទេសន្តរប្រវេសន៍ ថាជា **«ប្រទេស ជ័យលាភី នៃគំនិតផ្តួចផ្តើម របស់កតិកាសញ្ញាពិភពលោក ស្តីពី**

**ទេសន្តរប្រវេសន៍»** ក្នុងការប្តេជ្ញាចិត្តខ្ពស់ ការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ពលករទេសន្តរប្រវេសន៍ និងការពារពួកគេពីភាពរងគ្រោះ ដោយការរំលោភបំពាន និងកេងប្រវ័ញ្ច គ្រប់រូបភាព ។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ គ្រប់សមាសភាព នៃ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ដែលមាន ក្រសួង ស្ថាប័ន និងអង្គភាពជំនាញទាំង ២៧ ជាសមាជិក និងមានរចនាសម្ព័ន្ធតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ រួមជាមួយនឹងការចូលរួមគាំទ្រយ៉ាងសកម្មពី បណ្តាទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការដៃគូអន្តរជាតិ អង្គការសង្គមស៊ីវិលក្នុងស្រុក និងវិស័យឯកជន ដែលបានខិតខំប្រឹងប្រែងរួមគ្នា រិះរកគ្រប់មធ្យោបាយ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ ព្រមទាំងផ្តល់កិច្ចការពារជនរងគ្រោះ ទាំងស្ត្រី បុរស និងកុមារ និងបានចូលរួមដោះស្រាយបញ្ហាជាច្រើន សម្រាប់ប្រជាពលរដ្ឋតាមសហគមន៍ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលគ្មានសុវត្ថិភាព ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីអំពាវនាវដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងមានសមត្ថកិច្ចគ្រប់ប្រភេទ ព្រះសង្ឃ និងមេដឹកនាំសាសនាគ្រប់និកាយ បងប្អូនជនរួមជាតិទាំងអស់ ដូចខាងក្រោម៖

**១. ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ អាជ្ញាធរ កម្លាំងសមត្ថកិច្ច និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់**

- សូមខិតខំបំពេញភារកិច្ចឲ្យបានល្អ តាមតួនាទីដែលរាជរដ្ឋាភិបាលប្រគល់ឲ្យ ប្រកបដោយការទទួលខុសត្រូវ ខិតខំដោះស្រាយបញ្ហាដែលនៅសេសសល់ ដោយអនុវត្តតាមអភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុស**

ក្អែល ព្យាបាល និងវះកាត់» ដើម្បីធ្វើខ្លួនជាមន្ត្រីល្អ សក្តិសមនឹងការជឿទុកចិត្ត ពីរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ។

➢ ខិតខំតាមដានបាតុភាព និងបទល្មើសផ្សេងៗ និងគ្រប់គ្រងព្រំដែនឲ្យបានគត់មត់ ដើម្បីទប់ស្កាត់មូលហេតុរួមផ្សំ ដែលនាំឲ្យមានអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗ ។

➢ ពង្រឹង និងតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានាឲ្យមានប្រសិទ្ធភាព។

➢ កុំព្រងើយកន្តើយ ឬគាំទ្រអំពើល្មើសដែលកើតមាន ត្រូវខិតខំរួមគ្នាដោះស្រាយផ្តល់យុត្តិធម៌ដល់អ្នកដែលរងគ្រោះ ព្រមាន និងដាក់ទោសជនល្មើស ឲ្យសក្តិសមនឹងអំពើដែលបានប្រព្រឹត្ត ដើម្បីជាការលើកទឹកចិត្តដល់អំពើល្អ សុចរិតភាព និងយុត្តិធម៌ក្នុងសង្គម ។

➢ ខិតខំផ្សព្វផ្សាយអប់រំ តាមសាលារៀន តាមវេទិកាសហគមន៍នានា ជាពិសេស ក្នុងគោលនយោបាយភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព ឲ្យយល់ដឹងអំពីផលប៉ះពាល់នៃការប្រព្រឹត្តល្បែងស៊ីសងខុសច្បាប់ អំពើហិង្សា ការរំលោភបំពានលើស្ត្រី និងកុមារ អំពើជួញដូរមនុស្ស គ្រឿងញៀន និងគ្រឿងស្រវឹងគ្រប់ប្រភេទ ។

➢ រួមគ្នាលុបបំបាត់ការធ្វើទេសន្តរប្រវេសន៍ដែលគ្មានសុវត្ថិភាព ខុសច្បាប់ និងការងារខុសច្បាប់ ។

## ២. ចំពោះវិស័យសាសនា និងប្រជាពលរដ្ឋគ្រប់រូប

សូមថ្នាក់ដឹកនាំគ្រប់និកាយសាសនា មេត្តាបន្តការផ្សព្វផ្សាយខ្លឹមសារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សាសនិកទាំងឡាយ

នៅតាមសហគមន៍ទូទាំងប្រទេស ឲ្យបានយល់ជ្រួតជ្រាប ខ្លឹមសារ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមវិធានការដូចខាងក្រោម ៖

- **អប់រំ៖** គប្បីអប់រំស្មារតីប្រជាពលរដ្ឋ ដោយផ្អែកលើទស្សនទានសាសនា ឲ្យប្រព្រឹត្តតែអំពើល្អ សុចរិត មិនប្រើហិង្សា មិនរំលោភបំពាន ជាពិសេសលើស្ត្រី និងកុមារ បង្កើនការយល់ដឹងអំពីអំពើជួញដូរមនុស្ស កលល្បិចជនល្មើស និងផលប៉ះពាល់ដែលជាអំពើបាប និងត្រូវមានទោសធ្ងន់ធ្ងរតាមគោលការណ៍ច្បាប់ ។
- **ទប់ស្កាត់ និងការពារ៖** គប្បីរួមសហការគ្នា ការពារទប់ស្កាត់រាល់បទល្មើស ការពារកូនចៅ និងអ្នករស់នៅក្នុងសហគមន៍ ពីភាពរងគ្រោះ និងគប្បីផ្តល់ការអនុគ្រោះ ជួយការពារ គាំទ្រ និងអប់រំ ព្យាបាលរបួសផ្លូវចិត្តជនធ្លាប់រងគ្រោះ និងជួយតម្រង់ទិសរកភាពរីកចម្រើន ។
- **បង្ក្រាប៖** គប្បីរាយការណ៍ សហការ និងគាំទ្រអាជ្ញាធរ និងសមត្ថកិច្ចឲ្យធ្វើការស៊ើបអង្កេត និងបង្ក្រាបបទល្មើស និងជនល្មើស ដើម្បីសុវត្ថិភាពសហគមន៍ ។
- **ត្រូវចៀសវាង៖** កុំចូលរួម កុំគាំទ្រ កុំប្រព្រឹត្ត និងកុំទទួលផលពីអំពើទុច្ចរិត។

ម្យ៉ាងទៀត ទោះបីប្រទេសយើង មានស្ថានភាពធូរស្រាលពីការឆ្លង និងចម្លងកូវីដ-១៩ ហើយក៏ដោយ ក៏សូមអំពាវនាវទៅកាន់បងប្អូនជនរួមជាតិ សូមបន្តទទួលយកការចាក់វ៉ាក់សាំងបន្តទៀត នៅតាមទីតាំងដែលបានកំណត់ មានគ្រូពេទ្យចល័តតាមភូមិ តាមសាលារៀន តាមផ្ទះ និងតាមទីតាំងដែលបានកំណត់ និងសុំបន្តប្រកាន់ខ្ជាប់ វិធានការ បីកុំ បីការពារ ដើម្បីសេចក្តីសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងអ្នកជុំវិញខ្លួនពីមេរោគឆ្លងគ្រប់ប្រភេទ ។

ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់វិស័យពាក់ព័ន្ធជាតិ និងអន្តរជាតិ សូមបន្តរិះរកនូវវិធានការជាគន្លឹះនានា និងរួមសហការគ្នាជាធ្លុងមួយ ធ្វើសកម្មភាពឲ្យកាន់តែខ្លាំងក្លាក្នុងការ **«បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បី ព្រះរាជាណាចក្រកម្ពុជាគ្មានអំពើជួញដូរមនុស្ស»** ។ នេះជាការរួមចំណែកដ៏ធំធេង ក្នុងការលើកកម្ពស់ សន្តិសុខសុវត្ថិភាពសង្គម និងសន្តិភាពជាតិ ឲ្យមានស្ថេរភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ជាតិគ្រប់វិស័យ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាពតាមការគ្រោងទុក ។

សូមគ្រប់រាជធានី-ខេត្ត ឃុំ-សង្កាត់ និងតាមបណ្តាសាលារៀន ចាត់តាំងការរៀបចំផ្សព្វផ្សាយ តាមរូបភាពផ្សេងៗ នូវសារទាំងឡាយ នៃទិវា ១២ធ្នូ ប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ ៖ **«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព»** សម្រាប់ជាការពញ្ញាក់ស្មារតីឲ្យប្រជាពលរដ្ឋទាំងអស់ យល់ដឹងអំពីអំពើជួញដូរមនុស្ស និងចូលរួមបង្ការទប់ស្កាត់ និងការពារខ្លួនពីអំពើជួញដូរមនុស្ស ។

ជាទីបញ្ចប់នេះ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមលើកដៃបួងសួង ដល់បារមីវត្ថុសក្តិសិទ្ធិក្នុងលោក សូមលោកប្រទានពរសព្ទសាធុការ ថ្វាយ **ព្រះករុណា សម្តេចព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះវររាជមាតាជាតិខ្មែរ** សូមស្តេចប្រកបដោយព្រះរាជសុខភាពល្អ បរិបូរណ៌ ព្រះកាយពលមាំមួន ព្រះប្រាជ្ញាភ្លឺថ្លាវាងវៃ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅប្រជានុរាស្ត្រកម្ពុជា អស់កាលដ៏យូរអង្វែងតទៅ ។ សូមសម្តេចព្រះមហាសង្ឃរាជាទាំងពីរគណៈ ព្រះរាជាគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ មានព្រះជន្មាយុយឺនយូរ ព្រះសុខភាពល្អ ដើម្បីដឹកនាំសាសនាជាតិ

ឲ្យបានរុងរឿងតរៀងទៅ និងសូមសម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន លោក លោកស្រី លោកគ្រូ អ្នកគ្រូពេទ្យ កងកម្លាំងគ្រប់ប្រភេទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ថ្នាក់ដឹកនាំនិងសាសនិកគ្រប់និកាយសាសនា សហគមន៍អន្តរជាតិ សង្គមស៊ីវិលក្នុងស្រុក អ្នកសារព័ត៌មាន និងបងប្អូនជនរួមជាតិទាំងអស់ សូមមានសុខភាពល្អ និងសូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរព្រះគុណ និងសូមអរគុណ